Disability Rights California

*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# ការការពារ និងការតស៊ូមតិដើម្បីអ្នកទទួលជំនួយសន្តិសុខសង្គម (PABSS, Protection of Advocacy for Beneficiaries of Social Security)

***ឧសភា 2013 ឯកសារបោះពុម្ពផ្សាយលេខ #5430.06 - Cambodian***

## គោលបំណងនៃកម្មវិធី PABSS

គោលបំណងនៃកម្មវិធី PABSS គឺដើម្បីផ្តល់ព័ត៍មានដល់អ្នកទទួលជំនួយ (SSI, Supplemental Security Income) និង (SSDI, Social Security Disability Income) ព្រមទាំងផ្តល់ដំបូន្មានអំពីការទទួលបានសេវាកម្ម ស្តានីតិសម្បទាវិជ្ជាជីវៈ និងសេវាកម្មផ្សេងទៀតពាក់ព័ន្ធនឹងការងារ ។

កម្មវិធី PABSS ក៏តម្រូវឲ្យផ្តល់សេវាកម្មការតស៊ូមតិ និងសេវាកម្មផ្សេងទៀត ដែលអ្នកទទួលជំនួយត្រូវការដើម្បីធានាបាននូវសុវត្ថិភាពការងារ ឬទទួលបានមកវិញនូវការងារ ។

## អាទិភាពនៃកម្មវិធី PABSS

1. ស៊ើបអង្កេត និងពិនិត្យឡើងវិញនូវបណ្តឹងមកលើអ្នកផ្តល់សេវាកម្ម និយោជក ឬអង្គភាពពាក់ព័ន្ធនានា ដែលផ្តល់សេវាកម្មមិនសមរម្យ ឬមិនគ្រប់គ្រាន់ដល់អ្នកទទួលជំនួយដែលជាជនពិការ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យអ្នកទទួលជំនួយអាចត្រឡប់ទៅធ្វើការវិញបាន ។

2. ផ្តល់ព័ត៍មាន និងការបញ្ជូនបន្តដល់អ្នកទទួលផលសន្តិសុខសង្គមដែលមានពិការភាព អំពីការលើកទឹកចិត្តការងារ និងការងារ បូករួមទាំងព័ត៍មានអំពីប្រភេទសេវាកម្ម និងជំនួយដែល

អាចមានផ្តល់ជូន ដើម្បីជួយពួកគេក្នុងការរក្សាទុក ឬទទួលបានការងារមកវិញ ជាពិសេស សេវាកម្ម និងជំនួយដែលមានផ្តល់ជូនតាមរយៈបណ្តាញការងារ (EN, Employment Networks) ក្រោមកម្មវិធីលិខិតដើម្បីធ្វើការ និងកម្មវិធីភាពស្វាត់ជំនាញក្នុងខ្លួន (Ticket to Work and Self-Sufficiency program) ។

3. ផ្តល់ព័ត៌មាន និងជំនួយបច្ចេកទេស លើការលើកទឹកចិត្តការងារ ដល់អ្នកទទួលជំនួយដែលមានពិការភាព ។

4. ផ្តល់ការប្រឹក្សាយោបល់ និងធ្វើជាតំណាងផ្នែកច្បាប់ សម្រាប់អ្នកទទួលជំនួយដែលមានពិការភាព ស្តីអំពីបញ្ហាការត្រឡប់ទៅធ្វើការវិញ នៅពេលដែលសេវាកម្មបែបនេះក្លាយជាភាពចាំបាច់ ដើម្បីការពារសិទ្ធិអ្នកទទួលជំនួយបែបនេះ ។

5. ជួយដល់អ្នកទទួលជំនួយដែលមានពិការភាព ដែលមានជម្លោះចំពោះរដ្ឋបាលសន្តិសុខសង្គម (SSA, Social Security Administration)) ពាក់ព័ន្ធនឹងសេចក្តីសម្រេចអំពីកម្មវិធីពាក់ព័ន្ធនឹងការងារ ។

6. ផ្តល់ព័ត៌មាន និងជំនួយបច្ចេកទេសដល់ទីភ្នាក់ងាររដ្ឋាភិបាល បណ្តាញការងារ និងអ្នកផ្តល់សេវាកម្មផ្សេងទៀត ព្រមទាំងអង្គការធ្វើការងារផ្នែកតស៊ូមតិ ។

7. កំណត់រកចំនុចដែលត្រូវធ្វើការតស៊ូមតិ និងកែតម្រូវភាពខ្វះចន្លោះនៅក្នុងអង្គភាពជាអ្នកផ្តល់ជូនសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ សេវាកម្មការងារ និងសេវាកម្មគាំទ្រផ្សេងទៀត ដល់អ្នកទទួលផលដែលមានពិការភាព ។

## តើនរណាជាអ្នកមានសិទ្ធិចូលរួមកម្មវិធី PABSS?

### ដើម្បីមានសិទ្ធិចូលរួមក្នុងកម្មវិធី PABSS អ្នកត្រូវតែ ៖

1. ជាបុគ្គលដែលមានអាយុចាប់ពី 14 ឆ្នាំ ទៅដល់អាយុក្រោម 65 ឆ្នាំ

2. អ្នកទទួលជំនួយ SSI, SSDI ក្នុងពេលបច្ចុប្បន្ន ឬអ្នកដែលបច្ចុប្បន្នមានសិទ្ធិទទួលជំនួយពីកម្មវិធីនេះ (ត្រូវតែទទួលបានជំនួយជាប្រាក់) ។

3. អ្នកទទួលបានជំនួយជាប្រាក់ពី SSI/SSDI កាលពីពេលមុន ដោយសារពិការភាព ។

4. ឥឡូវទទួលបានជំនួយ MediCal និង/ឬទទួលជំនួយ 1619B ឬជំនួយ Medicare រួមទាំង Medicare Part D ។

5. បញ្ហាទាំងអស់ ត្រូវពាក់ព័ន្ធនឹងការងារ/កិច្ចការ ។

*SSA បានពិនិត្យឡើងវិញនូវអត្ថបទបោះពុម្ពផ្សាយខាងក្រោម ដើម្បីធានាបានចំពោះភាពត្រឹមត្រូវផ្នែកបច្ចេកទេសតែប៉ុណ្ណោះ ទោះជាយ៉ាងណាក៏ដោយ មិនត្រូវចាត់ទុកថាវាគឺជាឯកសារផ្លូវការរបស់ SSA ឡើយ ។*

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ [http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html](http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html)*